# ទស្សនវិជ្ជាគ្រិស្តសាសនានិងអ៊ិស្លាមសាសនា

*ដោយៈ បណ្ឌិត* **ហែម ឡាច**
*អនុប្រធាននាយកដ្ឋាននីតិសាស្ត្រ*
*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## ១-ទស្សនវិជ្ជាគ្រិស្តសាសនា

*គ្រិស្តសាសនា គឺជាសាសនាដែលមានសាសនិកច្រើនជាងគេបង្អស់ក្នុងចំណោមសាសនាធំៗនៃពិភពលោក។ ទស្សនវិជ្ជាគ្រិស្តសាសនា ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយគ្រប់ទ្វីបទាំងអស់។ ទស្សនវិជ្ជាគ្រិស្តសាសនាត្រូវបានផ្សព្វផ្សាយគ្រប់ទឹកដីនិងមានឥទ្ធិពលគ្របដណ្តប់លើផ្នត់គំនិតមនុស្សរាប់រយលាននាក់រួមទាំងខ្មែរយើងមួយចំនួនផងដែរ។*

### ១.១-ប្រវត្តិគ្រិស្តសាសនា

*-ប្រវត្តិព្រះយេស៊ូគ្រិស្ត*

*ព្រះយេស៊ូ បានប្រសូតកាលពីជាង ២០០០ឆ្នាំមុន ពីម្ដាយដែលជាស្ត្រីព្រហ្មចារីម្នាក់ឈ្មោះថា ម៉ារី នៅក្នុងក្រុងបេថ្លេហិម។*

*ព្រះអង្គបានចម្រើនវ័យធំឡើងដូចជាកុមារដទៃទៀតដែរ ដោយការធំឡើងទាំងរូបកាយ និងចិត្តគំនិត។ ទ្រង់បានរៀនវិជ្ជាជីវៈជាងឈើ ហើយប្រតិបត្តិតាមច្បាប់ធម្មជាតិ។ ទ្រង់មានចំណងខ្សែលោហិតដ៏ពិសេសជាមួយព្រះបិតាទ្រង់នៅស្ថានសួគ៌ ហើយបានបង្រៀនមនុស្សដែលមានចំណេះដឹងខ្ពស់ៗជាច្រើននៅឯព្រះវិហារបរិសុទ្ធ ក្រុងយេរូសាឡិម អំពីព្រះសូម្បីតែទ្រង់ទើបមានព្រះជន្មត្រឹមតែដប់ពីរព្រះវស្សារក៏ដោយ។*

*នៅពេលព្រះយេស៊ូពេញវ័យទ្រង់បានចាប់ផ្តើមបង្រៀនប្រជាជននៅក្នុងក្រុងយេរូសាឡិមអំពីព្រះ គឺដូចជាព្យាការីផ្សេងៗទៀតដែលបានបង្រៀនប្រជាជនរបស់ខ្លួនពីមុនទ្រង់ដែរ ប៉ុន្តែអ្វីដែលទ្រង់បង្រៀននោះគឺថ្មី។ ព្រះយេស៊ូ មានបន្ទូលឆ្លើយថា អ្នករាល់គ្នាជាពន្លឺនៃលោកិយ។ ឯទីក្រុងណា ដែលនៅលើភ្នំនោះលាក់មិនកំបាំងទេ។ ក៏គ្មានអ្នកអុជចង្កៀងយកទៅដាក់ក្រោមថាំងដែរ គេតែងដាក់លើជើងចង្កៀងវិញ នោះទើបភ្លឺដល់អ្នកដែលនៅក្នុងផ្ទះទាំងអស់គ្នា។ ដូច្នេះ ចូរឱ្យពន្លឺរបស់អ្នករាល់គ្នា បានភ្លឺនៅមុខមនុស្សលោកយ៉ាងនោះដែរ ដើម្បីឱ្យគេឃើញការណ៍ល្អដែលអ្នករាល់គ្នាប្រព្រឹត្ត រួចសរសើរតម្កើងដល់ព្រះវរបិតានៃអ្នករាល់គ្នាដែលគង់នៅស្ថានសួគ៌។*

*ព្រះអង្គមានបន្ទូលទៀតថា អស់អ្នកណាដែលផឹកទឹកនេះ នឹងត្រូវស្រេកទៀត៖ តែ*

អ្នកណាដែលផឹកទឹកខ្ញុំឱ្យ នោះនឹងមិនស្រេកទៀតឡើយ ទឹកដែលខ្ញុំឱ្យនឹងត្រឡប់ជារន្ធទឹកនៅក្នុងអ្នកនោះ ដែលផុសឡើងដល់ទៅបានជីវិតអស់កល្បជានិច្ច។ កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ។ រដ្ឋាភិបាលក្នុងមូលដ្ឋានទទួលអារម្មណ៍ថា ត្រូវបានគម្រាមកំហែងដោយការប្រកាស និង ការបង្ហាញខ្លួនអង្គទ្រង់ដល់សាធារណៈជន ហើយទ្រង់គឺជាអង្គគ្មានទោស ព្រះយេស៊ូ ត្រូវបានគេធ្វើគត។

ទ្រង់បានសុគតលើឈើឆ្កាង ប៉ុន្តែទ្រង់បានមានព្រះជន្មរស់ឡើងវិញពីផ្នូរ រយៈពេលបីថ្ងៃក្រោយពីការសុគត ។ ទ្រង់គឺជាអង្គដែលមានព្រះជន្មរស់ ដែលនឹងមិនសុគតម្តងទៀតឡើយ។បន្ទាប់ពីព្រះយេស៊ូទ្រង់ឡើងឋានសួគ៌ពួកសាវ័ក បានចេញទៅផ្សាយដំណឹងល្អគ្រប់ទិសទីក្នុងចក្រភព រ៉ូមទាំងមូល ហើយក៏មានមនុស្សជាច្រើនបានក្លាយជាគ្រិស្តបរិស័ទ ប៉ុន្តែចក្រភពរ៉ូមបានចាត់ទុកថា គ្រិស្តបរិស័ទជាសាសនាប្រឆាំងនឹងរដ្ឋ។ រដ្ឋអំណាចចក្រភពរ៉ូមបានបៀតបៀន ធ្វើទុក្ខបុកម្នេញដល់គ្រិស្តបរិស័ទដោយដុតទាំងរស់ ឆ្កាង កាត់ក និងដាក់ឱ្យតោស៊ី ដើម្បីបំបាត់គ្រិស្តបរិស័ទ។

គ្រិស្តសាសនិកបានកំណត់យកថ្ងៃទី ២៥ខែធ្នូ រៀងរាល់ឆ្នាំ ជាថ្ងៃបុណ្យសាសនាដែលជាថ្ងៃកំណើតរបស់ព្រះយេស៊ូ ហៅថាបុណ្យណូអែល។

*-ប្រវត្តិគ្រិស្តសាសនា*

សាសនាគ្រិស្តមានឫសគល់ចេញពីសាសនាយូដា។ នៅគ្រាដំបូងសាសនានេះបានចាប់ឫសលើទឹកដីចក្រភពរ៉ូម៉ាំងនិងតាមប្រទេសមួយចំនួនដែលឋិតនៅជុំវិញសមុទ្រមេឌីទែរ៉ាណេ រហូតដល់សមុទ្រខ្មៅប្រទេសរុស្ស៊ីឈូងសមុទ្រពែរ្សនិងប្រទេសឥណ្ឌា។ គ្រិស្តសាសនាបានរីកសាយភាយដល់អ៊ឺរ៉ុបខាងជើងយ៉ាងរហ័សក្នុងរយៈពេលតែ២ឬ៣សតវត្សរ៍ប៉ុណ្ណោះ សាសនានេះបានផ្សព្វផ្សាចូលដល់ទ្វីបអាស៊ីខាងលិចនិងអាហ្វ្រិកខាងជើង។

ចាប់ពីសតវត្សរ៍ទី១៦ នៅអាស៊ីខាងកើត អាហ្វ្រិកខាងត្បូងអាមេរិកខាងត្បូង និងអាមេរិកខាងជើង ក៏បានទទួលឥទ្ធិពលនៃគ្រិស្តសាសនានេះទៅតាមរយៈការធ្វើអាណានិគមរបស់ពួកអ៊ឺរ៉ុប។ បច្ចុប្បន្ននេះគ្រិស្តសាសនាបានបោះទីតាំងឈរជើងគ្រប់ទ្វីបទាំងអស់លើពិភពហើយ ត្រូវបានទទួលចំណាត់ថ្នាក់ខ្ពស់ជាងគេចំពោះអ្នកគាំទ្របែមទៀតផង។

គ្រិស្តសាសនាបានបោះជំហានចេញពីប្រទេសប៉ាលេស្ទីនទៅពាសពេញពិភពលោកទាំងមូលនៅគ្រប់ប្រទេសនិងនៅគ្រប់សម័យកាល។

គ្រិស្តសាសនាមានទម្រង់៣ក្នុងប្រវត្តិសាស្រ្តគឺៈ

-ព្រះសហគមន៍ដែលមានរចនាសម្ព័ន្ធ ក្នុងការផ្តល់អំណាចខាងផ្លូវវិញ្ញាណ ទៅលើ លោកអភិបាលទីក្រុងរ៉ូម ដែលទទួលកេរមត៌ក ពីសន្តសិលា ពេត្រុស។

-ព្រះសហគមន៍ដែលជាប្រជុំនៃព្រះ សហគមន៍ផ្សេងៗដែលមានឯករាជ្យ ហើយ ពាក់ព័ន្ធគ្នាតាមរយៈព្រះសហគមន៍ ដែលត្រូវ បានគ្រប់គ្រងអង្គប្រជុំ លោកអភិបាលផ្សេងៗ។

-សហគមន៍គ្រិស្តសាសនាដែលមិន មានរចនាសម្ព័ន្ធច្បាស់លាស់ទាំងអស់ មាន ប្រភពកំណើតពីព្រះយេស៊ូគ្រិស្ត ដែលបាន ត្រាស់ហៅសាវ័កឱ្យដើរតាម និងរស់នៅជាមួយ ព្រះអង្គ។

**-លំហូរចូលនៃគ្រិស្តសាសនាមកកម្ពុជា**

តាមឯកសាប្រវត្តិសាស្ត្រកម្ពុជារបស់អ្នក និពន្ធត្រឹង ងា បានឱ្យដឹងថា ជនជាតិព័រទុយ ហ្គាល់ និងអេស្ប៉ាញជាដើម ប៉ុនប៉ងយក សាសនាគ្រិស្តមកផ្សព្វផ្សាយនៅប្រទេសខ្មែរ យើងតាំងពីឆ្នាំ១៥៥៥នៃគ.ស.មកម្ល៉េះ តែ ទោះបីព្រះរាជាខ្មែរភាគច្រើនទ្រង់បានទទួល រាក់ទាក់ជួយសង់វិហារឱ្យពួកបព្វជិតផ្សាយ សាសនាគ្រិស្ត បែបណាក៏ដោយ ក៏ការ ផ្សព្វផ្សាយសាសនាថ្មីនេះពុំបានទទួល ជោគជ័យដូចបំណងដែរ។

បព្វជិតព្រះនាមហ្គាប៉ាជាក្រូសដែលជា អ្នកផ្សព្វផ្សាយសាសនាអឺរ៉ុបទី១ នៅប្រទេស ខ្មែរបានទទួលសារភាពថា មានខ្មែរតែម្នាក់គត់ ដែលបានចូលសាសនាគ្រិស្តជាមួយលោក ហើយជននោះបានទទួលមរណភាពទៅទៀត។ បព្វជិតអង្គនេះបានបញ្ជាក់បន្ថែមទៀតថា ក្រោយមកអ្នកផ្សាយសាសនាជនជាតិអឺរ៉ុបមាន ទំនាស់ជាមួយពួកព្រាហ្មណ៍ ក្នុងវាំង។ ខ្លួន លោកផ្ទាល់ក៏ត្រូវបានពួកព្រាហ្មណ៍អាក់អន់ ស្រពន់ចិត្ត ដោយលោកបានពន្យល់ដល់ប្រជា រាស្ត្រខ្មែរថា ព្រះអាទិទេពរបស់ពួកនេះ ពុំបាន បង្កើតមេឃ ទឹក និងដីនោះទេ ហើយអាទិទេព នោះជាមនុស្សកាចសាហាវ និងជាអ្នកប្រព្រឹត្ត បាបកម្មទៀតផង។

បព្វជិតតាសីហ្គា បានកត់ត្រាទុកថា បព្វជិតស៊ុលវែសបានលាងបាបឱ្យបានតែអ្នក ទោស និងជនបរទេស មាន ចិន ជប៉ុន ជ្វា តែ ខ្មែរគ្មានម្នាក់សោះ។ គេសង្កេតឃើញថា ការ ប៉ុនប៉ងបង្កើតអង្គការដោយសាសនាគ្រិស្តនៅ ប្រទេសខ្មែរត្រូវបានទទួលបរាជ័យជាបន្ត បន្ទាប់៖

-ការប៉ុនប៉ងលើកទី១ នៅក្នុងរជ្ជកាល ព្រះបាទសត្ថាទី១

-ការប៉ុនប៉ងលើកទី២ នៅក្នុងរជ្ជកាល ព្រះបាទរាមាជើងព្រៃ

-ការប៉ុនប៉ងលើកទី៣ នៅក្នុងរជ្ជកាល ព្រះបាទពញាតន់

-ការប៉ុនប៉ងលើកទី៤ នៅក្នុងរជ្ជកាល

ព្រះកែវហ្វាចៅពញាញោម។[1]

**១.២-ទស្សនវិជ្ជាគ្រិស្តសាសនា**

*-ត្រូវគោរពមាតាបិតា*

ការគោរពមាតាគឺជាទស្សនៈសង្គមដែលគ្រប់បុត្រធីតាត្រូវតែមានការដឹងគុណ ការតបគុណចំពោះលោកជារឿងធម្មតា។មនុស្សទូទៅបានឱ្យតម្លៃទៅលើការដឹងគុណនេះថាជាសីលធម៌មានតម្លៃខ្ពស់បំផុតសម្រាប់ជីវិតរស់នៅរបស់មនុស្ស។មិនមែនត្រឹមតែឪពុកម្ដាយនោះទេ នណារក៏ដោយដែលធ្លាប់មានឧបការគុណមកលើខ្លួនត្រូវតែដឹងគុណ ហើយចេះតបគុណគេទើបសង្គមរាប់អាន ឱ្យតម្លៃបុគ្គលនោះថាជាមនុស្សល្អ។

*-កុំយកទ្រព្យសម្បត្តិអ្នកដទៃ*

ចំណុចនេះពុំខុសគ្នាពីទស្សនៈរបស់ព្រះពុទ្ធសាសនានោះដែរ។ ការរស់នៅជាមនុស្សត្រូវមានសីលធម៌ក្នុងការរស់នៅនោះទើបជាការធ្វើឱ្យជីវិតរបស់ខ្លួនមានតម្លៃហើយការលួចឆក់ប្លន់ យកទ្រព្យសម្បត្តិអ្នកដទៃនោះគឺជាអំពើដែលអាក្រក់ដែលសង្គមស្អប់ខ្ពើម។ ចំណុចនេះបានសង្កត់ធ្ងន់ទៅលើសិទ្ធិមានកម្មសិទ្ធិរបស់មនុស្សអ្នកណាក៏មិនចង់ឱ្យទ្រព្យសម្បត្តិរបស់ខ្លួនដែលខិតខំស្វែងរកដោយញើសឈាមរបស់ខ្លួនបានទៅលើដៃមនុស្សដែលខ្ជិលដែលមិនខិតខំរកស៊ីចាំតែលួចឆក់យករបស់អ្នកដទៃមកធ្វើជារបស់ខ្លួននោះដែរ។ ការបាត់បង់ទ្រព្យសម្បត្តិ ធ្វើឱ្យម្ចាស់ទ្រព្យសម្បត្តិមានការក្ដៅក្រហាយឯអ្នកដែលយករបស់គេជួនកាលអាចត្រូវគេចាប់ដាក់គុកដាក់ច្រវាក់ក៏មាន។ដូច្នេះមនុស្សត្រូវតែចៀសវាងរៀរចាកការលួចឆក់ប្លន់ទ្រព្យសម្បត្តិរបស់ជនដទៃនេះឱ្យបាន។

*-កុំពោលពាក្យកុហក*

ពាក្យកុហកបោកបញ្ឆោតញុះញង់ជាហេតុនាំឱ្យមានការបែកបាក់គ្នា នាំឱ្យសង្គមមានការប្រេះឆានិងឈានទៅរកវិបត្តិទំនាស់អសន្តិសុខ។ កើតមកជាមនុស្សគប្បីប្រកាន់នូវពាក្យសច្ចៈ ពាក្យត្រឹមត្រូវ ទៀងត្រង់ ទើបប្រសើរ ទើបមានតម្លៃ។ អ្នកដែលប្រើពាក្យពិតមិនចេះបោកបញ្ឆោត បោកប្រាស់ កុហកអ្នកដទៃ ជននោះឯងគឺជាបុគ្គលជាទីស្រឡាញ់របស់មនុស្សផងទាំងពួង គេនាំគ្នាគោរពស្រឡាញ់រាប់អានកោតសរសើរ។ ឯអ្នកប្រព្រឹត្តបទកុហកបោកបញ្ឆោតវិញនោះ សង្គមស្អប់ខ្ពើមវាយតម្លៃថាជាមនុស្សអាក្រក់ថោកទាប។

ដូច្នេះមនុស្សពុំគប្បីប្រព្រឹត្តនូវការកុហកបោកបញ្ឆោតនោះទេ គួរប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវពាក្យពិត។ ពាក្យសច្ចៈនេះវាអាចនាំមកឱ្យសង្គមនូវការជឿទុកចិត្តគ្នាមានការរួបរួមគ្នា ជំរុញសង្គមឱ្យកាន់តែរីកចម្រើនបាន។

*-កុំលោភលន់ឱ្យសោះ*

[1] ត្រឹង ង៉ាៈ ***អរិយធម៌ខ្មែរ*** ការផ្សាយរបស់អ្នកនិពន្ធ គ.ស. ១៩៧៥

សារជាតិរបស់មនុស្សគឺពោរពេញទៅដោយដោយការលោភលន់ការចង់មានចង់បានមិនចេះចប់មិនចេះហើយ បានហើយចង់បានទៀត មានហើយចង់មានទៀត បានរបស់នេះវាត្រូវការរបស់នោះ។ សេចក្តីប្រាថ្នាចង់មានចង់បានហួសហេតុនេះនាំឱ្យមនុស្សរិះរកមធ្យោបាយបែបណា ធ្វើបែបណាដើម្បីខ្លួនទទួលបាននូវផលនោះ។ សេចក្តីលោភនេះបានជំរុញមនុស្សឱ្យប្រព្រឹត្តនូវអំពើថោកទាបគ្រប់បែបយ៉ាងដើម្បីទទួលផលដែលខ្លួនឯងចង់បាន។ ទង្វើអាក្រក់បែបនេះ សាសនាគ្រិស្តបានចាត់ទុកថា ជាសេចក្តីប្រាថ្នា ចង់បានប្រកបដោយភាពស្អុយគគ្រិចដូចលាមក។ បំណងប្រាថ្នាលាមក ជាគ្រោះថ្នាក់មួយចំពោះសេចក្តីសុខសាន្តមិនមែនសម្រាប់តែអ្នកដទៃនោះទេ សូម្បីតែខ្លួនឯងក៏ទទួលរងនូវគ្រោះថ្នាក់នេះផងដែរ។ យ៉ាងនេះហើយទើបព្រះយេស៊ូបញ្ញត្តមិនឱ្យមនុស្សប្រព្រឹត្តអំពើអាក្រក់ឡើយ។

*-ការជួយសង្គ្រោះ*

ព្រះយេស៊ូបានព្រមព្រៀងទទួលយកបានទាំងអស់ពីមនុស្ស។ ការធ្វើពលិកម្មគ្រប់បែបយ៉ាង សូម្បីតែជីវិត ជួយការពារមនុស្ស ជួយសង្គ្រោះមនុស្សឱ្យផុតពីក្តីលំបាកវេទនា ដោយទ្រង់បានជួយព្យាបាលជំងឺដល់មនុស្សខ្វាក់ខ្វិនពិការរហូតដល់អ្នកស្លាប់៣ថ្ងៃទៅហើយក៏ជួយឱ្យរស់ឡើងវិញដែរ។ ដោយសារទ្រឹស្តីនៃការជួយសង្គ្រោះនេះហើយ ទើបយើងឃើញលេចចេញនូវរូបរាងសហគមន៍ដើម្បីជួយមនុស្សទាំងឡាយណាដែលក្រីក្រតោកយ៉ាកជួបប្រទះការលំបាក អ្នកមានជំងឺតម្កាត់ជាដើម។ តាមក្រុម តាមភូមិនៃសហគមន៍កាលណាមាននរណាម្នាក់ឈឺគេនាំគ្នាចូលលុយគ្នាដើម្បីជួយអ្នកឈឺ ឬក្រុមគ្រួសារអ្នកឈឺ នោះជួនកាលជួយរកការងារឱ្យធ្វើជួយសង់ផ្ទះសម្បែង ឬបង្កើតមុខរបររកស៊ីថែមទៀតក៏មាន។ព្រះយេស៊ូចាត់ទុកការងារទាំងនេះជាកាតព្វកិច្ចរបស់មនុស្សគ្រប់រូបដែលត្រូវតែធ្វើឱ្យបានពុំអាចអាក់ខានបាននោះទេ។ នេះជាសិល្បៈនៃជីវិតរស់នៅដ៏ល្អត្រកាលដែលយើងហៅថាសិល្បៈនៃការចែករំលែក។

ជារួមមកយើងឃើញថា ទស្សនវិជ្ជាគ្រិស្តសាសនាមិនខុសគ្នាប៉ុន្មានពីទស្សនវិជ្ជាព្រះពុទ្ធសាសនា អ៊ិស្លាមសាសនា និងព្រហ្មញ្ញសាសនានោះទេ គឺស្វែងរកសេចក្តីសុខឱ្យមនុស្ស។

**១.៣-គោលការណ៍រួមមួយចំនួននៃជំនឿក្នុងគ្រិស្តសាសនា**

អ្នកកាន់គ្រិស្តសាសនាត្រូវបានបែងចែកជាក្រុមបក្ស ឬនិកាយរាប់រយនៅតាមបណ្តាប្រទេសនានានៅលើពិភពលោក។ និកាយនីមួយៗ ប្រកាន់យកគោលការណ៍ជំនឿ និងការគោរព ឬឱ្យតម្លៃទៅលើការបង្រៀនផ្សេងៗគ្នា។ ប៉ុន្តែ ពួកគេមានជំនឿមួយចំនួនដែលអាចចាត់ថាជាចំណុចរួម។

ខាងក្រោមនេះជាសម្រង់នៃគោលការណ៍រួមមួយចំនួននៃជំនឿក្នុងគ្រិស្តសាសនា៖

**-ទទួលព្រះវិញ្ញាណបរិសុទ្ធ៖** នៅពេលមនុស្សម្នាក់សម្រេចចិត្តជឿថាព្រះយេស៊ូជាព្រះអង្គសង្គ្រោះ ប្រចាំជីវិតរបស់ខ្លួន គាត់ក៏អធិដ្ឋានសុំទទួលព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះមកគង់ក្នុងចិត្ត។

**-ការអធិដ្ឋាន៖** ភាពខុសគ្នាដ៏ចម្បងនៃអ្នកជឿតាមគ្រិស្តសាសនានិកាយកាតូលិក និងប្រូតេស្តង់ គឺនៅត្រង់ចំណុចនេះឯង។ អ្នកជឿតាមនិកាយកាតូលិក ត្រូវអធិដ្ឋានសុំរួចបាប ឬសុំពរទាំងឡាយពីព្រះតាមរយៈលោកអាចារ្យម្នាក់ ព្រោះវិហារកាតូលិកបង្រៀនថា មានតែលោកអាចារ្យទេទើបអាចនិយាយផ្ទាល់ជាមួយព្រះបាន។ រីឯអ្នកជឿតាមនិកាយនានានៃក្រុមប្រូតេស្តង់ អាចនិយាយដោយផ្ទាល់ជាមួយព្រះ ទោះជាការសុំរួចបាប ឬសុំពរទាំងឡាយក៏ដោយ។

**-កំណើតអស្ចារ្យ៖** គ្រិស្តសាសនិកកាន់ជំនឿថា ព្រះយេស៊ូ កើតមកពីនាងម៉ារី ជាស្ត្រីក្រមុំព្រហ្មចារី មិនដែលរួមដំណេកជាមួយបុរសណាម្នាក់។ ពួកគេជឿថា ព្រះយេស៊ូ ជាវិញ្ញាណរបស់ព្រះបិតាដែលចុះមកខ្វីពោះនាងម៉ារី ដើម្បីចាប់កំណើតជាកូនមនុស្សលើផែនដី ដើម្បីឱ្យគេធ្វើគតជាថ្លៃលស់អំពើបាបរបស់មនុស្ស ដែលទទួលមកតាំងពីជំនាន់ អាដាំ និង នាង អេវ៉ា។

**-ថ្ងៃបរិសុទ្ធ៖** ថ្ងៃឈប់សម្រាក ជាថ្ងៃដែលអ្នកកាន់ជំនឿសាសនានេះទៅវិហារ ដើម្បីច្រៀងសរសើរព្រះ សុំរួចបាប សុំពរ និងជួបជុំជាសហគមន៍រួម។ ការកំណត់យកថ្ងៃសុក្រ ថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យជាថ្ងៃបរិសុទ្ធ វាស្រេចទៅលើនិកាយនីមួយៗ ជាអ្នកសម្រេច។ ពួកខាងកាតូលិកច្រើនជ្រើសរើសយកថ្ងៃសៅរ៍ រីឯពួកប្រូតេស្តង់ច្រើនជ្រើសយកថ្ងៃអាទិត្យ ជាថ្ងៃថ្វាយបង្គំព្រះ។

**-ព្រះយេស៊ូ គ្រិស្ត៖** ព្រះយេស៊ូ គ្រិស្ត ទ្រង់យាងមកផែនដីនេះ ដើម្បីសង្គ្រោះមនុស្សទាំងអស់ឱ្យរួចពីអំពើបាប ទ្រង់មានអំណាចនិងអាចសង្គ្រោះមនុស្សទាំងអស់បាន ដោយទ្រង់មានព្រះចេស្តាលើសេចក្ដីស្លាប់។ ព្រះយេស៊ូទ្រង់មានព្រះជនគង់នៅស្ថានសួគ៌ ទ្រង់បានយាងចុះមកយកនិស្ស័យជាមនុស្ស ទ្រង់បានបង្រៀនមនុស្សអំពីនគរស្ថានសួគ៌ ហើយបានសម្ដែងការអស្ចារ្យជាច្រើន ដូចជាប្រោសមនុស្សមានជំងឺឱ្យបានជា មនុស្សស្លាប់ឱ្យមានជីវិតរស់ឡើងវិញ។ ក្រោយមកមានមនុស្សខ្លះចង់ធ្វើគតព្រះអង្គ ហើយនៅថ្ងៃមួយទ្រង់ក៏ត្រូវគេចាប់ ហើយបានបញ្ជូនទៅដើម្បីធ្វើគតទ្រង់នៅលើឈើឆ្កាង ទ្រង់ក៏ត្រូវគេបញ្ចុះនៅក្នុងផ្នូរ ហើយបីថ្ងៃក្រោយមកទ្រង់ក៏មានព្រះជន្មរស់ឡើងវិញ។ ហើយ៤០ ថ្ងៃក្រោយពេលទ្រង់មានព្រះជន្មរស់ឡើងវិញ ទ្រង់ក៏បានយាងឡើងទៅកាន់ឋានសួគ៌វិញ

ហើយមានមនុស្សជាច្រើនបានឃើញទ្រង់ដែរ។ ទ្រង់ជាព្រះតែមួយអង្គគត់ ដែលជួយសង្គ្រោះមនុស្សជាតិ ជាអ្នកបង្កើតឋានសួគ៌និងភពផែនដី។ ទ្រង់ជាព្រះជាម្ចាស់ដ៏ពិតតែមួយ។

**-បុណ្យជ្រមុជទឹកៈ**ពិធីលាងបាបដោយទឹកអម្រឹតជាពិធីប្រសិទ្ធិ ដើម្បីដោះបាបកម្មដែលមនុស្សលោកបានធ្វើកន្លងមក ហើយក៏ផ្តល់នូវទឹកចិត្តថ្មីបរិសុទ្ធ ចំពោះមនុស្សទាំងនោះ។ពិធីលាងបាបច្រើនធ្វើនៅទីទឹកធម្មជាតិ ដូចជានៅទន្លេ នៅស្ទឹង នៅសមុទ្រ ឬ ទឹកចេញពីក្នុងដី។អ្នកបួសសាសនាគ្រិស្ត ជាអ្នករៀបចំពិធីលាងបាបក្នុងនាមព្រះយេស៊ូ គ្រិស្ត ជាព្រះអម្ចាស់។អ្នកបួសសាសនាគ្រិស្ត ជាអ្នកដែលធ្លាប់បានទទួលការលាងបាបដោយទឹកអម្រឹត និងមន្តអារម្មណ៍រួចហើយ។អ្នកដែលទទួលការលាងបាបត្រូវតែជ្រមុជខ្លួនទាំងស្រុងទៅក្នុងទឹក ដោយបង្អោនក្បាលនិងមុខមកក្រោម។

**-ការលាងបាតជើងៈ** ការប្រសិទ្ធី ដោយការលាងជើងទាំងពីរ អាចឱ្យគេចូលរួមជាមួយព្រះយេស៊ូ គ្រិស្ត ជាម្ចាស់។ នោះក៏ជាការដាស់តឿន ដ៏ទៀងទាត់មួយ ដល់មនុស្សលោក ឱ្យមានសេចក្តីស្រឡាញ់ ភាពស្ងប់អារម្មណ៍ ភាពលំឱនកាយ ភាពអត់ឱន និងភាពចេះជួយគ្នា។ មនុស្សរាល់គ្នា ដែលបានទទួលការលាងបាប ដោយទឹកអម្រឹតរួចហើយ ត្រូវតែមានជើងទាំងពីរលាងស្អាតជានិច្ច ក្នុងនាមនៃព្រះយេស៊ូ គ្រិស្តជាម្ចាស់។ ការត្រដុសជើងទាំងពីរ ជាទម្លាប់គ្រប់ពេល ដើម្បីបង្ហាញភាពគួរសម។

**-ព្រះគម្ពីរបរិសុទ្ធៈ** គឺជាព្រះបន្ទូលរបស់ព្រះ ដែលសរសេរតាមរយៈអ្នកនិពន្ធជាច្រើននាក់។ ព្រះគម្ពីរបរិសុទ្ធមាន៦៦សៀវភៅ ចែកជា សញ្ញាចាស់មាន ៣៩សៀវភៅ និងសញ្ញាថ្មីមាន ២៧សៀវភៅ។ ព្រះគម្ពីរបរិសុទ្ធបានសរសេរមក ទុកជាសេចក្តីបង្រៀន បំភ្លឺ ដាស់តឿន ដល់ព្រលឹងវិញ្ញាណ សម្រាប់មនុស្សទាំងអស់។

**-សេចក្តីសង្គ្រោះៈ**ការសង្គ្រោះត្រូវបានផ្តល់ឱ្យដោយព្រះជាម្ចាស់ តាមរយៈជំនឿ។ អ្នកដែលមានជំនឿលើទ្រង់ត្រូវតែពឹងពាក់លើវិញ្ញាណបរិសុទ្ធ ដើម្បីទទួលបានភាពបរិសុទ្ធ ដើម្បីលើកតម្កើងព្រះជាម្ចាស់ និងដើម្បីស្រលាញ់មនុស្សជាតិ។

**-ព្រះវិហារៈ** ១-ព្រះវិហារ ដែលកស្ថាបនា ដោយដៃមនុស្ស គឺជាអាគារ ឬកន្លែងថ្វាយបង្គំព្រះ ដែលគ្រិស្តសាសនិកអាចជួបជុំគ្នា រៀនព្រះបន្ទូល សរសើរ លើកតម្កើងព្រះ។ ២-ព្រះវិហារ ដែលព្រះ(ព្រះវិញ្ញាណបរិសុទ្ធ) គង់នៅនោះគឺជាព្រះវិហារនៅក្នុងចិត្តរបស់គ្រិស្តបរិស័ទម្នាក់ៗ។

**-សុភវិនិច្ឆ័យចុងបំផុតៈ** ព្រះយេស៊ូនឹងយាងចុះមកផែនដីជាលើកទីពីរ នៅក្នុងថ្ងៃចុងក្រោយបង្អស់របស់ពិភពលោក គឺទ្រង់យាងមកពីឋានសួគ៌នៅលើកនេះគឺទ្រង់សោយរាជ្យនៅផែនដី

ទាំងមូល ហើយទ្រង់និងវិនិច្ឆ័យពិភពលោកទាំងមូល គ្រានោះទ្រង់នឹងនាំមកនូវសន្តិភាពសម្រាប់ពិភពលោកទាំងមូល អស់អ្នកណាដែលទទួលទ្រង់ជាព្រះអម្ចាស់ហើយនោះនឹងបានទទួលនូវជីវិតអស់កល្បជានិច្ចនៅឯឋានសួគ៌ជាមួយនឹងទ្រង់។

**១.៤-ការរួមចំណែកនៃទស្សនវិជ្ជាគ្រិស្តសាសនាក្នុងសង្គម**

***-ការផ្តល់ជំនួយសង្គ្រោះ***

*ជាកត្តាមួយដ៏សំខាន់ដែលបានដក់ជាប់ក្នុងសន្តានចិត្តមនុស្សដែលកំពុងតែស្រេកឃ្លានហើយត្រូវបានគេផ្តល់ឱ្យនូវម្ហូបចំណី ទីជ្រកកោន ផ្តល់ជាសម្ភារប្រើប្រាស់ តាមទស្សនៈនៃការចែករំលែកជួយមនុស្សដូចគ្នា។ ទោះជាចង់ឬមិនចង់អារម្មណ៍ របស់មនុស្សពេលនោះត្រូវតែផ្អៀងទោរទន់ទៅរកសាសនាគ្រិស្តតាមរយៈការជួយរបស់ព្រះជាម្ចាស់មកលើពួកគេនោះជាមិនខាន។ បើពួកគេទោរទន់ឬចូលជាបរិស័ទនៃគ្រិស្តសាសនាត្រូវបានព្រះជួយសង្គ្រោះហើយការទទួលបានផលជាក់ស្តែងបែបនេះថែមទៀតនោះពួកគេពិតជាគ្មានរួញរាក្នុងចិត្តឡើយត្រូវតែទទួលយកប្រតិបត្តិតាមបញ្ញត្តិ ឬទស្សនៈស្តីពីជីវិតរស់នៅនិងការជួយគ្នាទៅវិញទៅមករបស់ព្រះយេស៊ូ។*

***-ការជួយស្វែងរកការងារឱ្យធ្វើ***

*ការទាក់ទាញទឹកចិត្តមនុស្សមួយទៀត គឺការខិតខំស្វះស្វែងរកការងារឱ្យប្រជារាស្ត្រដែលជួបការលំបាកឱ្យមានការងារធ្វើដើម្បីចិញ្ចឹមជីវិតបាន។ កត្តានេះក៏បានជះឥទ្ធិពលមិនតិចដែរមកលើសន្តានចិត្តប្រជាជនតាមរយៈការសង្គ្រោះមនុស្សពីភាពលំបាកតោកយ៉ាកទាំងនោះៗ តាមរយៈអង្គការមួយចំនួនដែលយកគោលការណ៍ព្រះគ្រិស្តជាប្រធានពេលចុះធ្វើសកម្មភាពនៅក្នុងប្រទេសមួយចំនួន គេតែងតែឆ្លៀតយកឱកាសខ្វះបញ្ជ្រាបនូវទស្សនៈស្តីពីជីវិតនិងភាពរស់នៅរបស់ព្រះយេស៊ូមកលើសន្តានចិត្តអ្នកជឿដូចជាការបើកសាលាបង្រៀនភាសាមិនយកលុយ ការជួយរកការងារឱ្យធ្វើ ការបណ្តុះបណ្តាលជំនាញផ្សេងៗ។*

***-ការបង្កើតសហគមន៍ព្រះគ្រិស្ត***

*រហូតមកដល់ពេលនេះ នៅតាមតំបន់ចុងកាត់មាត់ញកគេតែងសង្កេតឃើញសហគមន៍កាតូលិកប្រូតេស្តង់ឬសាវ័កថ្មីមាននៅស្ទើតែគ្រប់ទីកន្លែង ដោយបញ្ចុះបញ្ចូលអ្នកគាំទ្រឱ្យរៀនភាសាអង់គ្លេសក្នុងតម្លៃថោក ឬមិនបង់ប្រាក់។ មានក្រុមសហគមន៍ មានព្រះវិហារសម្រាប់ថ្វាយបង្គំ។ សហគមន៍ទាំងនោះគេបានបង្កើតនូវមូលនិធិរបស់គេនិងមានជំនួយពីបរទេសសម្រាប់ដំណើការ ក្នុងករណីពេលមានជំងឺឈឺថ្កាត់ មានគ្រោះវិបត្តិផ្សេងៗឬក៏តាមរូបភាពអែអង្គាសតាមជំនួយពីក្រៅ តាំងនាមព្រះជាម្ចាស់នៃការជួយសង្គ្រោះមនុស្ស។ តាមរយៈការងារនេះមានប្រជាជនមួយចំនួនបានចូលរួមគាំទ្រនិងធ្វើសកម្មភាពដើម្បីផ្សព្វផ្សាយទស្សនៈរបស់សាសនាគ្រិស្ត។*

បច្ចុប្បន្ន គ្រិស្តបរិស័ទបានចូលរួមសកម្មភាពសង្គមជាច្រើន តាមរយៈការអប់រំមនុស្សធម៌ និងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាល និងអង្គការសមាគមមានចរិតសាសនា ដូចជា ជួយសាងសង់សាលារៀន មណ្ឌលសុខភាព ផ្លូវ ស្ពាន អណ្តូងទឹក អំណោយមនុស្សធម៌ កាដូក្តីស្រឡាញ់ដល់កុមារ ក្មេងកំព្រារ ចាស់ជរា ។ល។

បន្ថែមពីលើនេះ គ្រិស្តសាសនា ក៏បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយពង្រឹង និងអប់រំសីលធម៌ ចរិយាធម៌សង្គម និងចូលរួមយ៉ាង សកម្មក្នុងការកសាង និងអភិវឌ្ឍសង្គមកម្ពុជា ឱ្យមានសុខសន្តិភាព ស្ថិរភាព រស់នៅប្រកបដោយភាពថ្លៃថ្នូរ និងសុខដុមរមនាជាមួយគ្នា មិនប្រកាន់និន្នាការជំនឿសាសនា វៀរចាកផុតពីការរើសអើង ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ អំពើហឹង្សាផ្សេងៗ ទាំងនៅក្នុងគ្រួសារ សហគមន៍ ក៏ដូចជានៅក្នុងសង្គមជាតិទាំងមូល។[2]

---

2 https://freshnewsasia.com/index.php/en/localnews/275600-2023-01-26-23-36-20.html




*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី ក្នុងពិធីអបអរសាទរខួប១០០ឆ្នាំនៃវត្តមានគ្រិស្តសាសនានៅកម្ពុជា ២៧ មករា ២០២៣ (ប្រភព៖ FRESH NEWS)*

## ២-ទស្សនវិជ្ជាអ៊ិស្លាមសាសនា

អ៊ិស្លាមសាសនា គឺជាសាសនាដែលមានសាសនិកច្រើនជាងគេលំដាប់ទី២ ក្នុងចំណោមសាសនាធំៗនៃពិភពលោក។ ប៉ុន្តែទោះបីជាអ៊ិស្លាមសាសនាជាសាសនាក្មេងខ្ចីជាងគេក៏ដោយ ក៏ទស្សនវិជ្ជាអ៊ិស្លាមសាសនា ត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងឆាប់រហ័សគ្រប់ទ្វីបទាំងអស់។ ទស្សនវិជ្ជាអ៊ិស្លាមសាសនាត្រូវបានផ្សព្វផ្សាយគ្រប់ទីកន្លែងនិងមានឥទ្ធិពលគ្របដណ្តប់លើផ្នត់គំនិតមនុស្សរាប់រយលាននាក់ក្នុងពិភពលោក រួមទាំងខ្មែរយើងមួយចំនួនផងដែរ។

### ២.១-ប្រវត្តិអ៊ិស្លាមសាសនា

*-ប្រវត្តិមហាម៉ាត់*

មហាម៉ាត់ជាសាស្ត្រាចារ្យជនជាតិអារ៉ាប់កើតនៅស្រុកមេកៈនៅគ.ស៥៧០។ គាត់ជាពូជពង្សរបស់ស្អែមគឺជាវង្សត្រកូលដែលមានឈ្មោះល្បីល្បាញទីទៅក្នុនពួកកូរៃឥច្ឆៈ គឺត្រកូលដែលជិតជាងជាងគេនៃគ្រួសារអ៊ីស្រាអែលបុត្រនៃអាទិទេពអាប្រាហាម។ចំណែកមាតារបស់លោកឈ្មោះ អាមីណាដែលជាបងប្អូនជាមួយលោកដែរ។ ក្រោយពេលឪពុកស្លាប់ម្តាយរបស់លោកបាននាំលោកមករស់នៅជាមួយលោកតាម៉ូតាលីបជាឪពុករបស់អេបដាឡាស់ឯក្រុងឡាមិចវិញ។កំណើតរបស់មហាម៉ាត់មានអព្ភូតហេតុដ៏អស្ចារ្យធ្វើឱ្យស្តេចម៉ូស៊ីស តាមរកចាប់ទារកមហាម៉ាត់មកសម្លាប់។ជីតារបស់លោកបាននាំលោករត់គេចទៅពួននៅវិហារចាស់មួយនៃជនជាតិអេចូពី។ពេលបានអាយុ៤ឆ្នាំម្តាយរបស់លោកបានទទួលមរណភាពហើយលោកត្រូវបានលោកតាម៉ូលីពជាអ្នកថែរក្សា។ ក្រោយពេលលោកតារបស់លោកលាចាកលោកទៅលោកបានមក

រស់នៅជាមួយឪពុកមាឈ្មោះអាប៊ូតាលីព។ ពេលមហាម៉ាត់បានអាយុ១៤ឆ្នាំលោកបាន ដឹកនាំទ័ពចូលប្រយុទ្ធក្នុងសមរភូមិជំនួសឪពុក មា។ លោកបាន បញ្ចេញបដិហារ្យធ្វើឱ្យសត្រូវ បាក់បបខ្ទបខ្ទាចរត់ចោលសមរភូមិអស់។ ចាប់ ពីពេលនោះមកឈ្មោះមហាម៉ាត់បានល្បីរន្ទឺ ឡើង។

បន្ទាប់មកកហាម៉ាត់បានរៀបការ ជាមួយនាងខាឌីហ្សា មិនយូប៉ុន្មានភរិយារបស់ លោកប្រសូត្របានបុត្រាមួយឈ្មោះថាកាស៊ីម ជាទូទៅគេច្រើនហៅកាត់ថាអាប៊ុលកាស៊ីម។ ក្រោយពេលអាប៊ុលកាស៊ីមស្លាប់ទៅលោក បានទៅសុំកូនឪពុកដែលចិញ្ចឹមខ្លួនឈ្មោះអា លីមកធ្វើជាកូន។មហាម៉ាត់មានភរិយា៦នាក់ មានកូនក៏ច្រើនដែរតែស្លាប់អស់សល់តែកូន ស្រីឈ្មោះហ្វាទីម៉ា ដែលលោកបានឱ្យទៅរៀប ការជាមួយអាលីកូនចិញ្ចឹមលោក។

នៅក្នុងវ័យគម្រប់៤០ឆ្នាំមហាម៉ាត់បាន ដកខ្លួនចេញពីសង្គម ទៅធ្វើការស្មិងស្មាធិ៍នៅ ក្នុងរូងភ្នំពេលនោះលោកបានជួបទេវតាមួយ ព្រះអង្គបានយកគម្ពីមួយមកឱ្យលោក។ មហាម៉ាត់បានចាប់ផ្តើមសិក្សាយល់ច្បាស់ ហើយបានដំឡើងខ្លួនជាចបីមានន័យថាការ យល់ដឹងគ្មានចន្លោះ។ ពេលនោះលោកបាន ប្រកាសបង្កើតសាសនាអ៊ិស្លាម។

មកដល់គ.ស៦១៤មហាម៉ាត់បាន រៀបចំពង្រីកសាសនារបស់ខ្លួនតែដោយលទ្ធិថ្មី នេះបាននាំមកនូវភាពផ្ទុយទាស់ដល់អ្នកផង ទាំងពួងធ្វើឱ្យគេមានគ្រោះថ្នាក់ជាច្រើន។ យ៉ាងណាមហាម៉ាត់បានរត់ចេញពីស្រុកមេក: ទៅរស់នៅស្រុកមេឌីន។ មិនយូប៉ុន្មាន មហាម៉ាត់បានលើកទ័ពទៅវាយពួកកុរ៉ៃតច្ឆ: លុះត្រាទទួលបានជោគជ័យ។

នៅក្នុងរវាង២ឆ្នាំ មុននឹងអាយុជីវិតចុង ក្រោយរបស់លោកមហាម៉ាត់បានផ្សព្វផ្សាយ សាសនារបស់លោកទទួលបាននូវបរិស័ទរាប់ សែននាក់នៅឆ្នាំ៦៣២នៃគ.ស។

-ប្រវត្តិអ៊ិស្លាមសាសនា

សាសនាអ៊ិស្លាមជាសាសនាដ៏ក្មេងខ្ចី មួយដែលទើបតែចាប់កំណើតនៅស.វទី៧។ ចាប់ពីឆ្នាំ៦១០ នៃគ.សសាសនានេះត្រូវបាន ប្រកាសផ្សាយដោយដាក់ឈ្មោះថាអ៊ិស្លាម។ ពាក្យអ៊ិស្លាមមានន័យថាស្រោចស្រង់សត្វលោ ក។ មកដល់គ.ស ៦១៤ មហាម៉ាត់បានចាប់ផ្តើម រៀបចំការផ្សព្វផ្សាយសាសនារបស់លោកក្នុង ទ្រង់ទ្រាយធំដោយមានការប្រជុំគណ: បាតិមោក្ខបុគ្គលធំៗនៅថ្ងៃទី១៦-០៧-៦២២ គឺ ជាការចាប់ផ្តើមហាម៉ាត់សកភពជ។កង់ទ័ព មហាម៉ាត់បានដណ្តើមយកព្រះវិហារកាអាបា ដែលជាបូជនីដ្ឋានគោរពបូជាបូជារបស់ពួកអា រ៉ាប់។

នៅក្នុងរវាង២ឆ្នាំមុនពេលស្លាប់ លោក បានបញ្ចុះបញ្ចូលបាននូវសាសនិកអ៊ិស្លាមរាប់ សែននាក់ឱ្យមកធ្វើការគោរពបូជាព្រះអាឡាហ៍

នៅស្រុកមេក:។ ចាប់តាំងពីឆ្នាំ៦៣២នៃគ.ស. មកឥទ្ធិពលនៃសាសនាអ៊ិស្លាមបានទទួលនូវការរីចម្រើនសាយភាយស្ទើរពេញពិភពលោក គឺរីកសាយភាយទៅដល់តំបន់អាហ្វ្រិច ប្រទេសស៊ីរីប៉ា ឡេស្ទីន អ៊ីរ៉ាក់ អ៊ីរ៉ង់ តំបន់កាបកាហ្ស បន្តរហូតដល់អាស៊ីភាគកណ្ដាល ហើយក្រោយមកបន្តដល់អាស៊ីភាគអាគ្នេយ៍។ បច្ចុប្បន្ននេះសាសនាអ៊ិស្លាមបានបោះទីតាំងឈរជើងគ្រប់ទ្វីបតែម្ដង។

តាមរយៈការសិក្សាស្រាវជ្រាវ យើងពុំទាន់រកឃើញឯកសារណាដែលបានបញ្ជាក់ឱ្យច្បាស់លាស់ថា តើសាសនាអ៊ិស្លាមបានចូលមកប្រទេសខ្មែរតាមរបៀបណា នៅសម័យកាលណាមួយឱ្យបានច្បាស់លាស់នោះទេ។ តែយើងគ្រាន់តែបានដឹងថានោស.វ ទី៨នៃ គ.ស នគរចេនឡាមានការបែកបាក់គ្នាយ៉ាងធំ គឺចេនឡាដីគោក និងចេនឡាទឹកលិច។ មូលហេតុនៃការបែកបាក់គ្នានេះហើយដែលជំរុញឱ្យពួកជ្វាឡើងចាងហើយចូលឈ្លានពាននគរខ្មែរតាមចិត្ត។ ពួកនេះបានហ៊ានទន្ទ្រានឈ្លានពានលើទឹកដីខ្មែរដោយរាជវង្សសៃលេន្ទ្រ:ដែលសើយរាជនៅកោះជ្វា និងជារាជវង្សស្ថាបនិកប្រាសាទបូរូបូឌូ ជាប្រាសាទដ៏ល្បីល្បាញដែលចេញផ្សព្វផ្សាយឥទ្ធិពលរបស់ខ្លួននៅលើអាស៊ីអាគ្នេយ៍នេះ។ យើងគិតថាប្រហែលជាមានការផ្សព្វផ្សាយសាសនាអ៊ិស្លាមលើទឹកដីខ្មែរនៅពេលនោះផងដែរ។

នៅសម័យអង្គរ នាឆ្នាំ១១៧៧ ស្ដេចចាមព្រះនាមជ័យឥន្ទ្រវរ្ម័នទី៤ បានវាយយកនគរខ្មែរត្រួតត្រារហូតដល់ឆ្នាំ១១៨១ ទើបជ័យវរ្ម័នទី៧ វាយរំដោះនគរពីពួកចាមឈ្លានពានបាន។ នៅក្នុងដំណាក់កាលប្រវត្តិសាស្ត្រនេះថ្វីដ្បិតតែយើងពុំមានកំណត់ត្រាណាមួយដែលទាក់ទងទៅនឹងការពង្រីកសាសនាអ៊ិស្លាមនៅលើទឹកដីខ្មែរក៏ដោយ ក៏ ឥទ្ធិពលនៃការត្រួតត្រារបស់ចាមនេះ ពិតជានាំមកតិច ឬច្រើននូវការផ្សព្វផ្សាយសាសនានោះជាមិនខាន។

តាមឯកសាររបស់លោកម៉ូលប្រ៊ុយណុង និងលោកស៊ុនហេងម៉េងឈាង ក្នុងសៀវភៅជនជាតិខ្មែរលោកបានបញ្ជាក់ថា ព្រះបាទពញាច័ន្ទបានឡើងគ្រងរាជនៅ គ.ស.១៦២១ នៅក្រុងឧដុង្គទ្រង់បានស្រឡាញ់ក្រមុំជ្វាហើយបានលើកនាងជាស្នំឯក ទ្រង់ក៏បានប្ដូរទៅកាន់សាសនាអ៊ិស្លាមវិញ ដោយប្ដូរព្រះនាមទ្រង់ជាអ៊ីប្រាហ៊ីម។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា សាសនាអ៊ិស្លាមពុំមែនទើបតែចូលមកផ្សព្វផ្សាយនៅលើទឹកដីខ្មែរនាស.វទី១៧ )១៦២១(នោះទេ គឺប្រហែលជាបានជះឥទ្ធិពលលើទឹកដីខ្មែរ តាំងពីចុងសម័យចេនឡាមកម្ល៉េះ។

### ២.២-ទស្សនវិជ្ជាអ៊ិស្លាមសាសនា

ទស្សនៈស្ដីពីជីវិត និងការរស់នៅរបស់សាសនាអ៊ិស្លាម ក៏ពុំខុសគ្នាប៉ុន្មានពីព្រះពុទ្ធសាសនា និងគ្រិស្ដសាសនាដែរ មានគោល

ដោតែមួយ គឺធ្វើបែបណាឱ្យមនុស្សអាចរស់នៅក្នុងសង្គមប្រកបដោយភាពថ្លៃថ្នូរ។

*-កុំលួចទ្រព្យអ្នកដទៃ*

កើតមកជាមនុស្សត្រូវកំណត់តម្លៃរបស់ខ្លួនឱ្យបានត្រឹមត្រូវ ត្រូវចេះរស់នៅក្នុងសង្គមប្រកបដោយសេចក្ដីថ្លៃថ្នូរ។ ការលួចឆក់ទ្រព្យអ្នកដទៃជាអំពើពុំល្អពុំគប្បីសម្រាប់ជីវិតនោះទេ។ ការធ្វើបែបនេះ នាំឱ្យអ្នកដទៃទទួលរងនូវភាពក្ដៅក្រហាយពីខ្លួន គេស្អប់ខ្ពើមមនុស្សប្រភេទនេះជាទីបំផុត។

*-កុំប្រើពាក្យកុហក*

បើប្រៀបជាមួយព្រះពុទ្ធសាសនា គឺធម៌មុសា។ មនុស្សដែលនិយាយមិនពិត បោកបញ្ឆោត កុហកអ្នកដទៃ គឺមិនមែនជាមនុស្សល្អនោះទេ។ មនុស្សប្រភេទនោះតាមរយៈសាសនាអ៊ិស្លាម គេចាត់ទុកថាជាមនុស្សអាក្រក់ ជាមនុស្សបាតសង្គម ធ្វើឱ្យសង្គមមានភាពច្របូកច្របល់ដោយសារការបោកបញ្ឆោតរបស់ខ្លួន។ មនុស្សប្រភេទនេះមិនមែនតែនៅក្នុងសាសនាអ៊ិស្លាមនោះទេ ក្នុងសង្គមបែបណាក៏គេពុំចាត់ទុកថាជាមនុស្សល្អមានភាពថ្លៃថ្នូរនោះទេតែគេចាត់ទុកថាជាមនុស្សថោកទាប។ ដូច្នេះ សាសនាអ៊ិស្លាមបានផ្ដល់ដំបូន្មានឱ្យមនុស្សចេះរស់ ចេះសម្របសម្រួលជីវិតរបស់ខ្លួនឱ្យសមជាមនុស្សថ្លៃថ្នូរ។

*-កុំសម្លាប់មនុស្ស*

សាសនាអ៊ិស្លាមក៏ជាសាសនាមួយបានផ្ដល់តម្លៃយ៉ាងខ្ពស់ដល់ជីវិតរស់នៅរបស់មនុស្សណែនាំមនុស្សឱ្យគោរពតម្លៃនៃជីវិតរបស់មនុស្សមិនត្រូវបៀតបៀនដល់ជីវិតមនុស្សនោះទេ។ ការប្រព្រឹត្តអំពើមនុស្សឃាតគឺជាសកម្មភាពអាក្រក់ជួជាតិបំផុតសម្រាប់មនុស្ស។ គេឱ្យតម្លៃបុគ្គលមួយថា ជាមនុស្សល្អទៅបាន លុះត្រាតែបុគ្គលនោះ ចេះយោគយល់អនុគ្រោះស្រឡាញ់មនុស្ស ឱ្យតម្លៃមនុស្សដូចគ្នា ព្រោះថាគ្មានអ្នកណាម្នាក់ចង់ស្លាប់ទេ សុទ្ធតែចង់រស់រានមានជីវិតដូចគ្នា។ នៅក្នុងករណីដែលមនុស្សអាច សម្លាប់គ្នាបានតាមចិត្តនោះ សង្គមពិតជាឈានទៅរកភាពកោលាហលមនុស្សពិតជារងនូវទុក្ខលំបាកគ្រប់ពេលវេលាមិនខាន។

*-កុំលួចប្រពន្ធគេ*

ទស្សនៈរបស់អ៊ិស្លាមសាសនាបានយល់ច្បាស់ណាស់នូវអ្វីដែលហៅថាជីវិតនៃការរស់នៅ ដោយលោកបានកំណត់ច្បាស់ថាអ្នកដែលមានប្រពន្ធកូនគេពិតជាស្រលាញ់ប្រពន្ធកូនគេជាមិនខាន ប្រសិនបើមានជនណាមកលួចឆក់យកកិរិយារបស់គេនោះតើគេមានការឈឺចាប់បែបណា។ករណីបែបនេះក៏បានបញ្ជាក់ថា សាសនានេះយល់ច្បាស់ពីបញ្ហាកម្មសិទ្ធ ពីសេរីភាពនៃជីវិតរបស់មនុស្សថែមទៀត ព្រោះថា មនុស្សជាជំពូកសត្វដែលមាន

វិចារណញ្ញាណ មិនមែនជាសត្វតិរច្ឆាននោះទេ។

**-ត្រូវមានយុត្តិធម៌ក្នុងសង្គមនិងបុគ្គលផ្ទាល់ខ្លួន**

ជាទូទៅបុគ្គលគ្រប់រូបមិនគ្រាន់តែប្រកាន់ឱ្យបានខ្ជាប់នូវយុត្តិធម៌សម្រាប់តែបុគ្គលនោះទេ តែមនុស្សក៏ត្រូវការពារថែរក្សាឱ្យបាននូវភាពយុត្តិធម៌សម្រាប់សង្គមដែលខ្លួនរស់នៅផងដែរ។ ហេតុអ្វីបានជាសាសនានេះយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាលើភាពយុត្តធម៌នៃសង្គមបែបនេះ។ ភាពយុត្តិធម៌ ជាភាពសុខដុមរមនានៃសង្គមបើសង្គមទទួលបាននូវភាពសុខសាន្តក៏មានន័យថាសមាជិកនៃសង្គមក៏ទទួលបាននូវសេចក្តីសុខផងដែរ។ ប៉ុន្តែផ្ទុយទៅវិញបើសង្គមមានភាពអយុត្តិធម៌នោះនឹងធ្វើឱ្យមានការបែកបាក់ប្រេះឆាហើយអ្នកដែលទទួលរងនូវទុក្ខទោសទារុណកម្មនោះគឺមនុស្សក្នុងសង្គមនោះឯង។ បែបនេះមានន័យថា ទ្រឹស្តីនេះបានយកចិត្តទុកដាក់ លើស្ថានភាពជីវភាពរស់នៅរបស់មនុស្ស។

**-ត្រូវមានអធ្យាស្រ័យដល់ស្ត្រីភេទនិងបំបាត់ការជួញដូរមនុស្ស**

**ត្រូវមានអធ្យាស្រ័យដល់ស្ត្រីភេទ៖** ទស្សនៈនេះ គឺជាការលើកកម្ពស់ស្ត្រីភេទ ដែលជាទូទៅគេនាំគ្នាគិតថាស្ត្រីភេទគ្មានប្រយោជន៍សម្រាប់សង្គមមនុស្សនោះទេ គេចាត់ទុកស្ត្រីគ្រាន់តែជាឧបករណ៍សម្រាប់លម្អសង្គមតែប៉ុណ្ណោះ។ទស្សនៈនេះត្រូវសាសនាអ៊ិស្លាមប្រឆាំងដាច់ខាត ដោយបានលើកកម្ពស់និងឱ្យតម្លៃលើស្ត្រីភេទប៉ុន្តែដោយស្ត្រីភេទមានភាពខ្សោយផ្នែកកំលាំងកាយនោះ ទើបលោកចែងថាត្រូវមានអធ្យាស្រ័យមានការអនុគ្រោះការសន្តោសប្រណីដល់ស្ត្រីភេទនោះ។ ស្ត្រីភេទ គឺជាប្រភេទមនុស្សមួយក្រុមដែលមិនអាចខ្វះបានក្នុងការកសាងសង្គមគ្រួសារ និងសង្គមជាតិទាំងមូលដែរ។

**បំបាត់ការជួញដូរមនុស្ស៖** មានការជួញដូរមនុស្សមានន័យថា សង្គមនោះជាសង្គមជិះជាន់សង្គមផ្តាច់ការនរណាចង់ធ្វើអ្វីបានស្រេចចិត្តឱ្យតែខ្លួនមានអំណាច។

ទស្សនៈនេះគឺជាការឱ្យតម្លៃយ៉ាងខ្ពស់ទៅលើសិទ្ធិមនុស្ស ពិសេសសិទ្ធរស់នៅ ដែលមិនត្រូវមានបុគ្គលណាអាចរំលោភបាននោះទេ។ ការរំលោភសិទ្ធិមនុស្ស នាំឱ្យមានការក្រោកឡើងដើម្បីទាមទារសិទ្ធិរស់នៅ សិទ្ធិមានជីវិត សិទ្ធិមានភាពថ្លៃថ្នូរជាមនុស្ស ហើយអ្វីៗដែលត្រូវវិនាសអន្តរាយនោះគឺជីវភាពរស់នៅរបស់មនុស្ស ជីវិតរបស់មនុស្សនេះឯង។

**-ការចេះចែករំលែកឱ្យទាន**

ទស្សនៈស្តីពីជីវិតនិងការរស់នៅលើចំណុចនៃការឱ្យទាននេះមានពីរប្រភេទ គឺការឱ្យទានប្រភេទទីមួយជាកាតព្វកិច្ចនៃជនមូស្លីមដែលត្រូវតែធ្វើដោយខានមិនបាន គឺថ្ងៃដែលបានចេញពីការធ្វើពិធីរ៉ាមាដាន។ ថ្ងៃនេះជាថ្ងៃ

ពិសេស ដែលគេត្រូវតែចែករមលែកធនធានដែលគេមាន ចែកជូនអ្នកក្រីក្រ។ ចំណែកការឱ្យទានប្រភេទទីពីរគឺពុំមែនជាករណី កិច្ចកាតព្វកិច្ចនៃជនមូស្លីមនោះទេ តែជាសាមានចិត្តរបស់ជនមូស្លីមដែលគេមានសិទ្ធាក្នុងការជួយសង្គ្រោះមនុស្ស។ នេះជាគោលទស្សនៈដែលល្អបំផុតសម្រាប់មនុស្សនិងការរស់នៅ ព្រោះរស់នៅជាមនុស្សត្រូវតែចេះជួយគ្នាទៅវិញទៅមក ដើម្បីភាពសុខសាន្តនៃជីវិត និងសុភមង្គល។

**-ថ្ងៃជំនុំជម្រះ**

សាសនាអ៊ិស្លាមក៏ពុំខុសពីសាសនាព្រះពុទ្ធដែរត្រង់ចំនុចនៃការប្រព្រឹត្តិ ហើយក៏មិនខុសគ្នាពីសាសនាព្រាហ្មណ៍ដែរ។ សាសនាព្រះពុទ្ធអ្នកសាងបាបកម្មអកុសលកម្ម នឹងត្រូវធ្លាក់ទៅរកទុក្ខវេទនាក្នុងឋាននរកអវចីយ៍។ ចំណែកសាសនាអ៊ិស្លាមវិញ ត្រូវទទួលទណ្ឌកម្មដោយឡែក គឺត្រូវឆ្លងកាត់ការកាត់ក្ដីរបស់ព្រះ។ អ្នកណាដែលធ្វើអំពើអាក្រក់លើជីវិតអ្នកដទៃ ត្រូវទទួលទោសដោយរុញទម្លាក់ទៅឋាននរក ឆេះដោយភ្លើង ឯអ្នកធ្វើអំពើល្អត្រូវកើតនៅឋានសួគ៌ សោយសុខ។ ការបង្កើតទ្រឹស្តីបែបនេះ មានន័យថា លោកចង់ទូន្មានឱ្យមនុស្សចេះស្គាល់តម្លៃមនុស្ស កុំឱ្យប្រព្រឹត្តិអំពើអាក្រក់ លាមកលើជីវិតមនុស្សដូចគ្នា ដើម្បីភាពសុខសាន្តរបស់មនុស្ស។

**២.៣-រ៉ាម៉ាឌន** (Ramadan)

រ៉ាម៉ាឌនជាខែមួយដ៏ពិសិដ្ឋសម្រាប់សាសនិកអ៊ិស្លាម។ ទី១៖ គួរអាន ដែលជាគម្ពីរពិសិដ្ឋ ត្រូវបានបញ្ចុះមកជាលើកដំបូងនៅក្នុងខែរ៉ាម៉ាឌននេះឯង នាឆ្នាំ៦១០ នៃគ.ស.។ ទី២៖ គឺការកាន់អំណត់តម ជាកាតព្វកិច្ចមួយក្នុងមូលដ្ឋានគ្រឹះទាំង៥នៃ សាសនាអ៊ីស្លាម។ កាតព្វកិច្ចកាន់អំណត់តមនេះ ត្រូវបានកំណត់ឱ្យអនុវត្ត នៅខែរ៉ាម៉ាឌន ចាប់តាំងពីឆ្នាំ ៦២៤ នៃគ.ស ពោលគឺ ២ឆ្នាំក្រោយ ការធ្វើហិជ្ជរ៉ស (ការចាកចេញ)ពីទីក្រុងមក្កះ ទៅក្រុងម៉ាឌីណះរបស់រ៉សូលុលឡោះ(មហាំម៉ាត់)។ ប៉ុន្តែវាមិនមែនជារឿងថ្មីស្រឡាងឡើយ នៅពេលដែលការកាន់អំណត់តមអាហារ ត្រូវកំណត់ឱ្យអនុវត្តក្នុងខែរ៉ាម៉ាឌននាជំនាន់ណា ពីមហាម៉ាត់នោះ ពីព្រោះកាតូកិច្ចនេះក៏ធ្លាប់ត្រូវបាន អនុវត្តរួចមកហើយនៅជំនាន់អ្នកពីមុនៗ ដូចជាជំនាន់អ៊ីប្រាហ៊ីម មូសា អ៊ីសា.... គ្រាន់តែរបៀប និងពេលវេលាខុសៗគ្នាតាមជំនាន់នីមួយៗប៉ុណ្ណោះ។

**បួស ឬខែបួស៖**ជាពាក្យត្រូវបានគេប្រើជាទូទៅដោយសំដៅទៅលើការប្រតិបត្តិមួយចម្បងនៅខែរ៉ាម៉ាឌន ដោយមិនពិសាអ្វីទាំងអស់នៅពេលថ្ងៃ។ ការមិនពិសាអ្វីទាំងឡាយនេះ ក្នុងភាសាអ៉ារ៉ាប់ គេហៅថា សោម(Saum) ដែលមានន័យថា «**តម**»។ អ្នកដែលជាប់កាតព្វកិច្ចតមអាហារនៅពេលថ្ងៃក្នុងខែរ៉ម៉ាឌននេះ គឺមូស្លីម ប្រុសស្រីដែលមានអាយុ (១៣

ឬ១៥ឆ្នាំ) ឡើងទៅ និងមិនមែនជាមនុស្សពិការសតិបញ្ញា។ តែក្នុងករណីសម្រាប់អ្នកមានជំងឺ អ្នកធ្វើដំណើរតាមផ្លូវឆ្ងាយ នារីពពោះ ឬមានរដូវ នារីបំបៅកូនជាដើម អាចមានសិទ្ធិមិនបួសបាន តាមហេតុការណ៍កើតឡើងជាក់ស្ដែង តែត្រូវសងវិញនៅពេលក្រោយ រីឯអ្នកចាស់ជរាមិនអាចបួសបានតែម្ដងត្រូវផ្ដល់អំណោយទានដល់អ្នកក្រីក្រ ក្នុងមួយថ្ងៃ អង្ករកន្លះគីឡូ នារយៈពេលមួយខែពេញ នៃខែរ៉ាម៉ាឌន។

បន្ថែមពីលើនេះ ការតមនេះគឺតមលើការបរិភោគក្នុងពេលវេលា ដែលហាមឃាត់ចាប់ពីទៀបភ្លឺ រហូតដល់ថ្ងៃលិច។ នៅអំឡុងពេលថ្ងៃ គេមិនត្រូវបរិភោគ ផឹក ឬការមានទំនាក់ទំនងផ្លូវភេទនោះទេ ចំណែកឯការមករដូវរបស់ស្ត្រី ក៏ធ្វើឱ្យខូចនូវការតមនេះដែរ។ ទោះជាយ៉ាងនេះក្ដី ការបរិភោគដោយអចេតនា ឬភ្លេចភ្លាំង មិនត្រូវបានចាត់ទុកថា ដាច់ ឬខូចដល់ការកាន់អំណត់តមនោះឡើយ។

**ការកាន់អំណត់តមមិនមែនជាទណ្ឌកម្មទេ៖** រយៈពេលនៃការតមក្នុងមួយថ្ងៃៗ វែង ឬខ្លី គឺអាស្រ័យតាមដំណើរគោចរនៃព្រះអាទិត្យតាមតំបន់ ឬប្រទេសនីមួយៗ ព្រោះគេនឹងចាប់តមអាហារពីពេលទៀបភ្លឺ និងចាប់ពិសារវិញនៅពេលថ្ងៃលិច។ ក៏ប៉ុន្ដែ គេត្រូវគប្បីយល់ឲ្យបានច្បាស់ថាការកាន់អំណត់ នេះពុំមែនជាការដាក់ទោស ឬទណ្ឌកម្ម ឬទុក្ខកិរិយាទៅលើមនុស្សជាតិ ឬក៏ជាភារៈដែលមិនអាចទ្រាំទ្របាននោះទេ។ គោលគំនិតសំខាន់នៅពីក្រោយនៃការអនុវត្តការតមអំណត់នេះ គឺជាការធ្វើសក្ការៈដោយសុទ្ធចិត្តទៅចំពោះការបង្គាប់បញ្ជារបស់អល់ឡោះជាម្ចាស់ ដូចទ្រង់មានព្រះបន្ទូលក្នុងគម្ពីរគួរអានដូច្នេះថា៖ **«ឱ! បណ្ដាអ្នកមានជំនឿលើអល់ឡោះ និងអ្នកនាំសាររបស់អល់ឡោះគឺមហាម៉ាត់ អល់ឡោះជាម្ចាស់បានដាក់កាតព្វកិច្ចលើពួកអ្នកឱ្យតមអំណត់អាហារនៅពេលថ្ងៃ ដូចគ្នាទៅនឹងអល់ឡោះបានដាក់កាតព្វកិច្ចលើបណ្ដាអ្នកដែលមានជំនឿពីមុនៗ ដើម្បីសម្ដែងការកោតខ្លាចនិងគោរពតាមបទបញ្ជាដោយសុទ្ធចិត្តទៅចំពោះអល់ឡោះ»**[3]

ម្យ៉ាងវិញទៀត ការកាន់អំណត់នេះមិនមែនត្រឹមជាការកាត់បន្ថយការបំពេញតម្រូវការផ្នែកសារពាង្គកាយ ពីការបរិភោគនិងផឹកពីច្រើនមកតិចនោះទេ ប៉ុន្ដែវាគឺជាការតាំងចិត្ត រាងពងកាយនិងការសម្អាតវិញ្ញាណ ពីតម្រូវការផ្នែកសម្ភារៈនិយម ការអត់ធ្មត់ មានម្ចាស់ការលើតណ្ហា ឬសេចក្ដីស្រេកឃ្លាន និងជាពិសេសការអនុវត្តនូវធម៌វិន័យក្នុង ឋានៈជាសាវ័ក ដែលប្រកាន់ខ្ជាប់នូវគោលជំនឿត្រឹមត្រូវ។

**ការអនុវត្តផ្សេងៗក្នុងខែរ៉ាម៉ាឌន៖** ខែរ៉ាម៉ាឌន ជាខែដែលត្រូវសង្វាតប្រព្រឹត្តអំពើល្អ

---

3 https://freshnewsasia.com/index.php/en/localnews/333152-2024-03-21-06-47-50.html

ដោយឱកាសនេះមានមិនលើសពីមួយខែនោះឡើយ។ អំពើល្អទាំងនោះមានដូចជាការផ្តល់ចំណីអាហារដល់អ្នកកាន់អំណត់តម ជនទីទ័លក្រ ការបរិច្ចាកទានៗល។ ទោះជាយ៉ាងនេះក្តី ក៏មានការអនុវត្តដែលមិនត្រឹមត្រូវផ្សេងពីការអប់រំនៃសាសនាអ៊ិស្លាមដែរ។ មានមនុស្សមួយចំនួនបានធ្វើការចំណាយដោយខ្ជះខ្ជាយនៅអំឡុងពេលកាន់អំណត់ លើមុខម្ហូបរបស់ខ្លួនតាំងពីពេលចាប់ផ្តើម និងពេលបញ្ចប់។ ពួកគេរៀបចំអាហារហាក់ ដូចសម្រាប់ចំនួនមនុស្សកុះករ ហើយចុងបញ្ចប់ ពួកគេហូបត្រឹមតែបន្តិចបន្តួចប៉ុណ្ណោះ ហើយអាហារដែលនៅសល់ គឺបានត្រឹមតែបោះបង់ចោល។ ការអនុវត្តបែបនេះ គឺផ្ទុយនឹងក្រឹតក្រមវិន័យនៃសាសនាអ៊ិស្លាម។

គួរបញ្ជាក់ឡើងវិញថា របៀបបួស ឬតមអាហារ គឺត្រូវអនុវត្តតាមស៊ុនណះ (អ្វីដែលមហាម៉ាត់បានធ្វើ) ពោលគឺការចាប់ផ្តើមបួសនៅថ្ងៃដំបូងនៃខែរ៉ាម៉ាឌន នោះត្រូវមើលព្រះចន្ទ នៅថ្ងៃមួយកើតនៃខែ រ៉ាម៉ាឌន។ តែបើមើលមិនឃើញព្រះចន្ទទេ គេត្រូវបំពេញខែសាក់ពឺន (ខែទី០៨ នៃមហាម៉ាត់សករាជ) ឱ្យគ្រប់៣០ថ្ងៃ នោះទើបជនមូស្លីមអាចចាប់ផ្តើមបួសនៅថ្ងៃមួយកើត ខែរ៉ាម៉ាឌន។




*សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីពិសាអាហារស្រាយបួសខែរ៉ាម៉ាឌននៃអ៊ិស្លាមសាសនានៅកម្ពុជា ២១ មីនា ២០២៤ (ប្រភព៖ FRESH NEWS)*

## ២.៤-ការរួមចំណែកនៃទស្សនវិជ្ជាអ៊ិស្លាមសាសនាក្នុងសង្គមខ្មែរ

ទោះបីជាអ្នកកាន់សាសនាអ៊ិស្លាមនេះមានចំនួនតិចតួចនៅលើទឹកដីខ្មែរយើងក៏ដោយ ក៏ប៉ុន្តែឥទ្ធិពលនៃទ្រឹស្តីសាសនានេះនៅតែបានគ្របដណ្តប់លើសន្តានចិត្តកូនខ្មែរដែរជាពិសេសបណ្តាបងប្អូនជនជាតិខ្មែរអ៊ិស្លាមទាំងអស់។ ដោយទស្សនៈនេះជាទស្សនៈមនុស្សនិយម អប់រំមនុស្សឱ្យចេះស្រលាញ់មនុស្ស ចេះឱ្យតម្លៃមនុស្ស កុំប្រព្រឹត្តអ្វីទាំងឡាយដែលរំលោភបំពានដល់ ជីវិតរបស់ជនដទៃនោះ

*ទាំងនេះគឺជាសីលធម៌ដែលបានផុសចេញពីសាសនានេះចំពោះសន្តានចិត្តកូនខ្មែរផងដែរ។*

*តាមរយៈការសិក្សាទៅលើទស្សនៈស្តីពីជីវិតនិងការរស់នៅរបស់មនុស្សតាមរយៈបណ្តាទស្សនៈនៃពាហិរសាសនាធំៗមាន ព្រាហ្មណ៍សាសនា គ្រិស្តសាសនា និងអ៊ិស្លាមសាសនាជាដើម ទោះជាមានចំណុចខ្វះបាននិយាយទាក់ទងទៅនឹងអាទិទេពទាក់ទងទាក់ទងទៅនឹងជាតិក្រោយ ស្ថាននរកស្ថានសួគ៌ខ្វះក៏ពិតមែន ប៉ុន្តែជាតុពិតនៃទស្សនៈនិងទ្រឹស្តីរបស់សាសនាទាំងនោះសុទ្ធតែបានបង្កើតឡើងដើម្បីកែច្នៃកែសម្រួលជីវិតមនុស្សឱ្យស្ថិតនៅក្នុងសភាពថ្លៃថ្នូរត្រឹមត្រូវសមរម្យជាមនុស្ស។ ការរស់នៅប្រកបទៅដោយភាពថ្លៃថ្នូរចេះធ្វើជីវិតរបស់ខ្លួនឱ្យសម្រុងនឹងសង្គមព្រមទាំប្រតិបត្តិគ្រប់គោការណ៍ទាំងអស់ដើម្បីជីវិតនៃការរស់នៅក្នុងសង្គមនោះគឺជាតម្រូវការចាំបាច់របស់សាសនាទាំងនោះ។*

*ទស្សនៈសាសនាណាក៏កែច្នៃមនុស្សឱ្យប្រព្រឹត្តិតែអំពើល្អ កុំរំលោភបំពានកុំប៉ះពាល់ផលប្រយោជន៍របស់មនុស្សដូចគ្នា ត្រូវចេះជួយគ្នា ចែករំលែកគ្នាដើម្បីសេចក្តីសុខស្ងេរភាព និងសន្តិសុខនៃសង្គម។ ជាងនេះទៅទៀតការអប់រំមនុស្សត្រូវតែប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសុចរិតធម៌ សាមគ្គីធម៌ ការអត់ឱនការយោគយល់ ការអធ្យាស្រ័យដល់មនុស្សដូចគ្នា។ បើមនុស្សម្នាក់ៗបានកែច្នៃជីវិតរបស់ខ្លួនទៅតាមទស្សនៈនៃសាសនាទាំងនោះ។ប៉ុន្តែពុំមែនមានន័យថា ជឿលិចលង់ងប់ងល់ដោយខ្វះការពិចារណានោះទេ។ ការធ្វើបែបនេះជាតម្រូវការចាំបាច់របស់សង្គម ដែលជាហេតុនាំឱ្យសង្គមមនុស្សក្លាយទៅជាសង្គមល្អបរិសុទ្ធមានស្ថេរភាព សន្តិភាព និងការអភិវឌ្ឍរីកចម្រើនល្អត្រកាល។៚*

## គន្ថនិទ្ទេស


*១-ជួន ណាតៈ **វចនានុក្រមខ្មែរ** ភ្នំពេញ ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ គ. ស. ១៩៦៧*

*២-ត្រឹង ង៉ាៈ **អារិយធម៌ខ្មែរ** ការផ្សាយរបស់អ្នកនិពន្ធ គ. ស. ១៩៧៥*

*៣-ច សោះ **ព្រហ្មញ្ញសាសនា និងសង្គមខ្មែរ** ភ្នំពេញ ការផ្សាយរបស់អ្នកនិពន្ធ គ. ស. ១៩៩៤*

*៤-ប៉ែន សាអឿនៈ **សាសនាប្រៀបធៀប** ការផ្សាយរបស់អ្នកនិពន្ធ គ. ស. គ. ស. ១៩៦៩*

*៥-យូ នួនៈ **ទស្សនគតិសាសនា** ការផ្សាយរបស់អ្នកនិពន្ធ ឆ្នាំ១៩៩៧*

៦-https://freshnewsasia.com/index.php/en/localnews/275600-2023-01-26-23-36-20.html

៧-https://freshnewsasia.com/index.php/en/localnews/333152-2024-03-21-06-47- 50.html